# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ ១៨២១ កបទ.សអ.សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ
## ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៩១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៤ ចុះថ្ងៃ ទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការ តែងតាំងមុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីកែសម្រួលមាត្រា៦ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ និងបំពេញបន្ថែមមាត្រា៣៤ថ្មីស្ទួន និងមាត្រា៣៩ស្ទួន របស់អនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និង ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និង ភារកិច្ច និង សិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី
- បានឃើញសេចក្តីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបប ការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរបស់រដ្ឋាភិបាល
- បានឃើញសេចក្តីសម្រេចលេខ ៦៥ សសរ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងរដ្ឋលេខាធិការ ប្រចាំការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១**.-

ត្រូវបានបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចខាងក្រោម៖

### I - ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការងារទាំងអស់លើវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

### II - រដ្ឋលេខាធិការប្រចាំការ និងរដ្ឋលេខាធិការ ៖

| | | |
|---|---|---|
| ១- | ឯកឧត្តម **ស៊ា កុសល** | រដ្ឋលេខាធិការប្រចាំការ ជួយរដ្ឋមន្ត្រីលើការងារដឹកនាំ និងគ្រប់គ្រងក្រសួង និងជួយដឹកនាំផ្ទាល់លើការងារធនធានមនុស្ស កិច្ចការច្បាប់ កុងស៊ុល និងព្រំដែន ។ |
| ២- | ឯកឧត្តម **ឈីវ យីស៊ាង** | ជួយរដ្ឋមន្ត្រីលើការងារវាយតម្លៃ និទស្សន៍ វិភាគ និងព្យាករណ៍អំពីការវិវត្តនៃស្ថានការណ៍ជាតិ និងអន្តរជាតិ(IRAG) និងការងារពាក់ព័ន្ធនឹងអង្គការហ្វ្រង់កូហ្វូនី។ |
| ៣- | ឯកឧត្តម **ចែម វីឌ្យា** | ជួយរដ្ឋមន្ត្រីលើការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប។ |
| ៤- | លោកជំទាវ **សឿង រដ្ឋចាវី** | ជួយរដ្ឋមន្ត្រីលើការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក និងជួយដឹកនាំដោយផ្ទាល់តំបន់អាស៊ី-អាគ្នេយ៍។ |
| ៥- | លោកជំទាវ **ទូត បញ្ញា** | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីខាងកើត។ |

| | | |
|---|---|---|
| ៦- | ឯកឧត្តម គង់ ភោគ | ជួយរដ្ឋមន្ត្រីលើការងារអាស៊ាន និងជាឧត្តមមន្ត្រីអាស៊ានរបស់កម្ពុជា។ |
| ៧- | ឯកឧត្តម ជុំ សុន្ទរី | ជួយរដ្ឋមន្ត្រីលើការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្ដាប្រទេសនៅតំបន់អាមេរិក អាហ្វ្រិក និង មជ្ឈិមបូព៌ា។ |
| ៨- | លោកជំទាវ យ៉ិនទៀង ពុទ្ធរស្មី | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារអង្គការអន្តរជាតិ និងជួយសម្របសម្រួលការងារទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម។ |
| ៩- | ឯកឧត្តម ឃួន ផុនរតនៈ | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្ដាប្រទេសនៅ តំបន់អឺរ៉ុប តំបន់មជ្ឈិមបូព៌ា និងកិច្ចការឥស្លាម។ |
| ១០- | ឯកឧត្តម កាន់ ផារិទ្ធ | ជួយរដ្ឋមន្ត្រីលើការងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងការងារប្រតិបត្តិការថែរក្សាសន្តិភាព។ |
| ១១- | ឯកឧត្តម មាស គឹមហេង | ជួយរដ្ឋមន្ត្រីលើការងារកិច្ចសហប្រតិបត្តិការអន្តរជាតិទូទៅ កិច្ចសហប្រតិបត្តិការមេគង្គ, ACD, ACMECS, CLV, CLMV និង CICA។ |
| ១២- | ឯកឧត្តម ប្រាក់ ផល្លា | ជួយរដ្ឋមន្ត្រីលើការងារឌីជីថលូបនីយកម្ម (Digitalization) ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា e-visa និង e-passport ។ |
| ១៣- | ឯកឧត្តម កេត សោផាន់ | ជួយរដ្ឋមន្ត្រីលើការងារគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ និងជួយថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា។ |
| ១៤- | ឯកឧត្តម ខេង សិទ្ធិគុណា | ជួយរដ្ឋមន្ត្រីលើការងាររដ្ឋបាល និងទំនាក់ទំនងសាធារណៈ។ |
| ១៥- | លោកជំទាវ ខៀវ សុផានី | ជួយរដ្ឋមន្ត្រីលើការងារហិរញ្ញវត្ថុ អធិការកិច្ច និងសវនកម្ម និងការងារការទូតសេដ្ឋកិច្ច។ |
| ១៦- | ឯកឧត្តម ប្រាក់ ងួនហុង | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធ លើការងារសហប្រតិបត្តិការជាមួយអាស៊ីកណ្ដាល អាស៊ីខាងត្បូង និងតំបន់ប៉ាស៊ីហ្វិក។ |
| ១៧- | ឯកឧត្តម លឹម វិសាល | ទទួលបន្ទុកជានាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ |
| ១៨- | ឯកឧត្តម អ៊ុន យាង | ជួយរដ្ឋមន្ត្រីលើការងារវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ និងសម្របសម្រួលការងារសហប្រតិបត្តិការទ្វេភាគី និងពហុភាគី។ |
| ១៩- | ឯកឧត្តម ឃី សុវណ្ណរតនា | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការអន្តរជាតិទូទៅ។ |

III - **អនុរដ្ឋលេខាធិការ ៖**

| | | |
|---|---|---|
| ១- | ឯកឧត្តម កែវ វិសិដ្ឋ | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារ កិច្ចការច្បាប់ កុងស៊ុល និងព្រំដែន។ |
| ២- | លោកជំទាវ រត្ន ម៉ានី | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការ ក្របខ័ណ្ឌមេគង្គ ACD, ACMECS, CLV និង CLMV CICA ។ |
| ៣- | ឯកឧត្តម ណុំ ពិសិដ្ឋ | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការ ទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាមេរិក។ |
| ៤- | ឯកឧត្តម អ៊ឹង រចនា | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារអាស៊ាន។ |
| ៥- | ឯកឧត្តម បុង សុវត្ថិ | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារ UNESCO និង ការងារវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ។ |
| ៦- | ឯកឧត្តម អាន សុខខឿន | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារនាយកដ្ឋានព័ត៌មាន និងបញ្ហាសិទ្ធិមនុស្ស និងជាអ្នកនាំពាក្យក្រសួង។ |
| ៧- | ឯកឧត្តម ចាយ ណាវុធ | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង។ |
| ៨- | ឯកឧត្តម អ៊ឹក សោភ័ណ | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារការទូតសេដ្ឋកិច្ច។ |
| ៩- | ឯកឧត្តម កែ សុវណ្ណ | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារអង្គការ សហប្រជាជាតិ។ |
| ១០- | ឯកឧត្តម ចាន់ រតនា | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន។ |
| ១១- | លោកជំទាវ ផែន សាវនី | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការ ទ្វេភាគីជាមួយបណ្តាប្រទេសនៅតំបន់អឺរ៉ុបកណ្តាលអឺរ៉ុបខាងកើត និងរុស្ស៊ី។ |
| ១២- | ឯកឧត្តម សោម វិសាល | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការ ទ្វេភាគី នៅតំបន់អាស៊ីកណ្តាល និងអាស៊ីខាងកើត ។ |
| ១៣- | លោកជំទាវ ទូច សុផារត្ន | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារសហប្រតិបត្តិការ ជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងសហប្រតិបត្តិការតំបន់ និងសហប្រតិបត្តិការពហុភាគី អាស៊ី និងអឺរ៉ុប។ |
| ១៤- | ឯកឧត្តម ភិន វិជ្ជាវឌ្ឍនា | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារទំនាក់ទំនង សាធារណៈ។ |
| ១៥- | ឯកឧត្តម ឈួយ ប៊ុនឈាង | ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារឌីជីថលូបនីយកម្ម (Digitalization) ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា e-visa និង e-passport ។ |

១៦- ឯកឧត្តម **ទី នីតូប្ប** ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធលើការងារការទូតសេដ្ឋកិច្ច។

១៧- ឯកឧត្តម **ឡុង យ៉េស** ជួយរដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំពាក់ព័ន្ធកិច្ចការឥស្លាម។

**ប្រការ ២**.-

រដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការខាងលើអាចទទួលភារកិច្ចតាមការចាត់តាំងក្នុងក្របខ័ណ្ឌក្រុមប្រឹក្សា គណៈកម្មាធិការ គណៈកម្មការ ក្រុមការងារអន្តរក្រសួង និងផ្ទៃក្នុងក្រសួង និងអាចទទួលភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ ៣**.-

ការបែងចែកប្រគល់ភារកិច្ចដូចមានកំណត់ក្នុងសេចក្តីសម្រេចនេះអាចធ្វើការកែសម្រួលក្នុងករណីចាំបាច់។

**ប្រការ ៤**.-

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥**.-

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធានគ្រប់ស្ថានបេសកកម្មក្រៅប្រទេស ប្រធានគ្រប់អង្គភាពចំណុះក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**សុខ ចិន្តាសោភា**

**កន្លែងទទួល**:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥ « ដើម្បីអនុវត្ត »
- ឯកសារ កាលប្បវត្តិ